**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

– ភសរ: ១៣៤ រសម

# សេចក្តីសម្រេច

## ស្តីពី

## គោលការណ៍នៃការតែងតាំងទីប្រឹក្សានិងជំនួយការនៃរដ្ឋសភា

## ប្រធានរដ្ឋសភា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៧/០០៤ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- យោងលទ្ធផលនៃសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ នាថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការជ្រើសតាំងថេនាសម្ព័ន្ធដឹកនាំរដ្ឋសភានិងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រដ្ឋសភា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីគោលការណ៍ លក្ខខណ្ឌ និងបែបបទ សម្រាប់ការការតែងតាំងទីប្រឹក្សា និងជំនួយការនៃរដ្ឋសភា ដែលរួមមាន ទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញមុខងារ។

**មាត្រា២.-**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា លើកលែងតែទីប្រឹក្សានិងជំនួយការរបស់គណៈកម្មការ



CamScanner

នានានៃរដ្ឋសភា ក្រុមប្រឹក្សា ឬយន្តការនានា ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់រដ្ឋសភា។

សេចក្ដីសម្រេចនេះ មិនមានវិសាលភាពអនុវត្តចំពោះខុទ្ទកាល័យប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់រដ្ឋសភា។

## ជំពូកទី២

## លក្ខខណ្ឌនិងបែបបទនៃការតែងតាំងទីប្រឹក្សានិងជំនួយការ

**មាត្រា៣.-**

រដ្ឋសភា មានទីប្រឹក្សា និងជំនួយការតាមការចាំបាច់។ ទីប្រឹក្សានិងជំនួយការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសេចក្ដីស្នើរបស់ប្រធានរដ្ឋសភា ឬត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ប្រធានរដ្ឋសភា។

ប្រធាននិងអនុប្រធានរដ្ឋសភា មានទីប្រឹក្សានិងជំនួយការតាមការចាំបាច់។ ទីប្រឹក្សានិងជំនួយការត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសេចក្ដីស្នើរបស់ប្រធានរដ្ឋសភា ឬត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ប្រធានរដ្ឋសភា។

**មាត្រា៤.-**

ទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា មិនអាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ដើម្បីយកទៅអនុវត្តនៅក្នុងមុខតំណែងនៃក្របខណ្ឌមន្ត្រីរាជការអគ្គលេខាធិការដ្ឋានរដ្ឋសភាឡើយ។

**មាត្រា៥.-**

ការតែងតាំងទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១-មន្ត្រីនយោបាយ ឬបុគ្គលផ្សេងទៀត ដែលមិនស្ថិតនៅក្នុងក្របខណ្ឌជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាល ឬយោធិន អាចទទួលបានការតែងតាំងជាទីប្រឹក្សា ឬជំនួយការរដ្ឋសភា ដោយបានទទួលការផ្ដល់ឋានៈស្មើ បន្ថែមលើមុខងារបច្ចុប្បន្ន និងប្រាក់បំណាច់កម្រិតណាមួយបាន ។

២-ការតែងតាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ឱ្យបំពេញមុខងារជាទីប្រឹក្សាឬជំនួយការរដ្ឋសភា ទីប្រឹក្សាឬជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា បន្ថែមលើមុខងារបច្ចុប្បន្ន មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តភារកិច្ចជាមន្ត្រីរាជការ ហើយមិនមានការផ្ដល់ឋានៈស្មើ និងប្រាក់បំណាច់ឡើយ។

៣-មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន អាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការនៃរដ្ឋសភា បន្ថែមលើមុខងាបច្ចុប្បន្នបាន ក្នុងលក្ខខណ្ឌដែលមន្ត្រីរាជការសាមីនោះ មិនទទួលបានការផ្ដល់ឋានៈស្មើ និងប្រាក់បំណាច់បន្ថែមកម្រិតណាមួយឡើយ។

CamScanner

៤.មេធាវី ឬអ្នកវិជ្ជាជីវៈសេរី ដែលកំពុងប្រកបវិជ្ជាជីវៈអាចទទួលការតែងតាំងជាទីប្រឹក្សា ឬជំនួយការរដ្ឋសភា និងទីប្រឹក្សា ឬជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

៥.មេធាវី ឬអ្នកវិជ្ជាជីវៈសេរី ដែលមិនប្រកបវិជ្ជាជីវៈអាចទទួលការតែងតាំងជាទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ដោយទទួលបានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយបាន។

៦.បុគ្គលដែលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជន ឬបុគ្គលដែលទទួលបានគោរមងារឧកញ៉ា អាចទទួលបានការតែងតាំងជាទីប្រឹក្សា ឬជំនួយការរដ្ឋសភា ក្នុងលក្ខខណ្ឌដែលមិនមានការផ្តល់ឋានៈស្មើ និងប្រាក់បំណាច់កម្រិតណាមួយឡើយ។

**មាត្រា៦.-**

មុខតំណែងទីប្រឹក្សានិងជំនួយការរដ្ឋសភា ត្រូវបញ្ចប់នៅពេលចប់នីតិកាលនីមួយៗនៃរដ្ឋសភា។

មុខតំណែងទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ត្រូវបញ្ចប់នៅពេលដែលប្រធាននិងអនុប្រធានរដ្ឋសភា ត្រូវបានបញ្ចប់មុខតំណែង។

## ជំពូកទី៣
## អំពីប្រាក់បំណាច់ទីប្រឹក្សានិងជំនួយការនៃរដ្ឋសភា

**មាត្រា៧.-**

ទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ដែលមានឋានៈស្មើ ទទួលបានប្រាក់បំណាច់ប្រចាំខែ តាមសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៨.-**

ក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃសេចក្តីសម្រេចនេះ ទីប្រឹក្សានិងជំនួយការរដ្ឋសភា ទីប្រឹក្សានិងជំនួយការប្រធានរដ្ឋសភានិងអនុប្រធានរដ្ឋសភា ដែលត្រូវបានតែងតាំងរួចហើយទទួលបានការផ្តល់ឋានៈស្មើ ត្រូវដាក់ពាក្យសុំនៅក្រៅក្របខណ្ឌដើម។ ផុតពីរយៈពេល ៦ខែ នេះ ប្រាក់បំណាច់មុខងារជាទីប្រឹក្សា និងជំនួយការត្រូវកាត់ផ្តាច់ និងជំនួសដោយប្រាក់បំណាច់មុខងារនៅតាមអង្គភាពដើមរបស់មន្ត្រីរាជការនោះវិញ។

CamScanner

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

សេចក្តីសម្រេចនេះ ត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣កើត ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០២៣
ប្រធានរដ្ឋសភា

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី**

__ចម្លងជូន__ :
- គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតអនុប្រធានទី១រដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២រដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងបុគ្គលិក

  "ដើម្បីអនុវត្តិ"
- ឯកសារ-កាលប្បវត្តិ

CS CamScanner